ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ស្ថានឯកអគ្គរាជទូតកម្ពុជា
ប្រចាំប្រទេសជប៉ុន

# សេចក្តីប្រកាសព័ត៌មាន

## កម្ពុជាបង្ហាញពីបេតិកភណ្ឌវប្បធម៌របស់ខ្លួននៅក្នុងព្រឹត្តិការណ៍សប្តាហ៍ហ្វ្រង់កូហ្វូនី នៅទីក្រុងតូក្យូ

តូក្យូ ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៦ — ស្ថានឯកអគ្គរាជទូតនៃព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសជប៉ុន បានចូលរួមក្នុងព្រឹត្តិការណ៍សប្តាហ៍ហ្វ្រង់កូហ្វូនីឆ្នាំ២០២៦ ដែលប្រារព្ធឡើងនៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៦ នៅវិទ្យាស្ថានភាសាបារាំងនៃទីក្រុងតូក្យូ ប្រទេសជប៉ុន ដោយបានរៀបចំស្តង់វប្បធម៌មួយដែលបង្ហាញពី បេតិកភណ្ឌ ប្រពៃណី ផលិតផលក្នុងស្រុកដ៏សម្បូរបែបរបស់កម្ពុជា និងទំនាក់ទំនងដ៏រស់រវើករបស់ខ្លួនទៅកាន់ពិភពហ្វ្រង់កូហ្វូន។

ក្នុងព្រឹត្តិការណ៍នេះ ឯកឧត្តម **ជុំ សុន្ទរី** ឯកអគ្គរាជទូតនៃព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសជប៉ុន បានអញ្ជើញចូលរួមជាមួយឯកអគ្គរាជ/រដ្ឋទូត ភារធារី និងតំណាងស្ថានទូតនៃប្រទេស/រដ្ឋជាសមាជិកនៃអង្គការអន្តរជាតិហ្វ្រង់កូហ្វូនី(OIF)ប្រចាំប្រទេសជប៉ុន។ ព្រឹត្តិការណ៍នេះត្រូវបានសហការរៀបចំឡើងដោយក្រុមប្រឹក្សាលើកតម្កើងហ្វ្រង់កូហ្វូនីនៅជប៉ុន(CPFJ) និងស្ថានទូតនៃប្រទេស/រដ្ឋជាសមាជិកOIF និងស្ថាប័នហ្វ្រង់កូហ្វូនផ្សេងទៀត។

ព្រឹត្តិការណ៍ខាងលើ បានផ្តល់ឱ្យអ្នកទស្សនាជប៉ុននិងសហគមន៍អន្តរជាតិ នូវឱកាសស្វែងយល់ពីវប្បធម៌កម្ពុជា កន្លែងទាក់ទាញទេសចរណ៍ ផលិតផលខ្មែរ និងការចូលរួមយូរអង្វែងរបស់កម្ពុជានៅក្នុងសហគមន៍ហ្វ្រង់កូហ្វូន។ នេះក៏ជាវេទិកាដ៏មានតម្លៃសម្រាប់ការផ្លាស់ប្តូរវប្បធម៌ និងការសន្ទនាក្នុងចំណោមបណ្តាប្រទេសហ្វ្រង់កូហ្វូន និងសាធារណជនជប៉ុនផងដែរ។

ឆ្លៀតក្នុងឱកាសនោះ ស្ថានទូតបានតាំងបង្ហាញនូវស្នាដៃសិល្បៈ និងចែកជូននូវសៀវភៅផ្សព្វផ្សាយនានាដែលបង្ហាញពីប្រវត្តិសាស្ត្រ អត្តសញ្ញាណវប្បធម៌ និងគោលដៅទេសចរណ៍សំខាន់ៗរបស់កម្ពុជា ព្រមទាំងការចាក់បញ្ចាំងវីដេអូផ្សព្វផ្សាយដែលកម្ពុជាជាប្រទេសម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនី ដែលគ្រោងនឹងប្រព្រឹត្តទៅនៅថ្ងៃទី ១៥-១៦ ខែវិច្ឆិកា ឆ្នាំ២០២៦។



8-6-9 AKASAKA, MINATO-KU, TOKYO 107-0052
Tel : +81 3-5412-8521 Fax: +81 3-5412-8526
Email: camemb.jpn@mfaic.gov.kh

សូមកត់សម្គាល់ផងដែរថា តាមការស្នើរបស់ស្ថានឯកអគ្គរាជទូតកម្ពុជា មុខម្ហូបខ្មែរ "សាច់គោឡុកឡាក់" ត្រូវបានបង្ហាញនៅក្នុងបញ្ជីមុខម្ហូបរបស់ភោជនីយដ្ឋាន L'Oiseau de France ដែលមានទីតាំងនៅក្នុងវិទ្យាស្ថានភាសាបារាំងនៃទីក្រុងតូក្យូ និងជាទីតាំងនៃការរៀបចំព្រឹត្តិការណ៍។ ការដាក់បញ្ចូលមុខម្ហូបកម្ពុជាដ៏ល្បីនេះបានផ្តល់ឱ្យអ្នកទស្សនានូវរសជាតិនៃកេរដំណែលស្នាដៃម្ហូបខ្មែរ និងបានបន្ថែមនូវមុខម្ហូបដ៏ពិសេសមួយនៅក្នុងព្រឹត្តិការណ៍នេះ។

ក្នុងនាមជាប្រទេសសមាជិកដ៏សកម្មនៃអង្គការអន្តរជាតិហ្វ្រង់កូហ្វូនី កម្ពុជាបន្តលើកកម្ពស់កិច្ចសហប្រតិបត្តិការផ្នែកវប្បធម៌ និងភាសាបារាំង។ ការចូលរួមក្នុងព្រឹត្តិការណ៍នានា ដូចជាសប្តាហ៍ហ្វ្រង់កូហ្វូនី នៅទីក្រុងតូក្យូ បានឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តរបស់កម្ពុជាក្នុងការពង្រឹងការទូតវប្បធម៌ និងលើកកម្ពស់មិត្តភាពរវាងបណ្តាប្រទេសប្រើប្រាស់ភាសាបារាំង និងប្រទេសជប៉ុន។

ថ្ងៃចន្ទ ១៣រោច ខែផល្គុន ឆ្នាំម្សាញ់ សប្តស័ក ព.ស ២៥៦៩

តូក្យូ ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៦